**<u>កម្មវត្ថុ៖ កិច្ចប្រជុំក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន ដោយផ្ទាល់ និងមានជម្រើសតាមអនឡាញ – ថ្ងៃទី 11 ខែមិថុនា ឆ្នាំ 2026</u>**

ភាគីពាក់ព័ន្ធយុត្តិធម៌បរិស្ថានទាំងអស់ជាទីគោរព!

ការិយាល័យប្រតិបត្តិកិច្ចការថាមពល និងបរិស្ថាន (EEA) សូមអញ្ជើញក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន (EJC) មកកិច្ចប្រជុំបន្ទាប់របស់ខ្លួននៅថ្ងៃទី 11 ខែមិថុនា ឆ្នាំ 2026 វេលាម៉ោង 6:30 ល្ងាច។ (ម៉ោងស្តង់ដារខាងកើត)។ សមាជិកក្រុមប្រឹក្សានឹងពិភាក្សាអំពី Microgrids និងបទបញ្ញាប្រតិបត្តិស្តីពីការផ្តត់ផ្គង់ថាមពល។ ផ្នែកដែលបានកំណត់នៃកិច្ចប្រជុំនឹងត្រូវរក្សាទុកសម្រាប់មតិសាធារណៈទូទៅ។

**សូមចុះឈ្មោះសម្រាប់កិច្ចប្រជុំតាមរយៈតំណភ្ជាប់នេះ៖**
https://www.zoomgov.com/webinar/register/WN_opu8sC1lRF2KgC28H9u5Fw

**ការរៀបចំកិច្ចប្រជុំ៖** កិច្ចប្រជុំនេះនឹងត្រូវបានរៀបចំជាលក្ខណៈចូលរួមដោយផ្ទាល់នៅមជ្ឈមណ្ឌល Hitchcock Center សម្រាប់ផ្នែកបរិស្ថាន និងមានជម្រើសចូលរួមតាមប្រព័ន្ធ Zoom ។ កិច្ចប្រជុំនេះត្រូវបានប៉ាន់ស្មានថាមានរយៈពេល 90 នាទី។ អគារប្រជុំមានទីតាំងស្ថិតនៅ 845 West St, Amherst, MA 01002 ។ អាចធ្វើដំណើរទៅដល់បានតាមរយៈខ្សែរថយន្តក្រុងលេខ 31, 38, 38NS និងលេខ 39 (សូមមើលមគ្គុទ្ទេសក៍ bus guide) ។ សម្រាប់ការណែនាំអំពីផ្លូវធ្វើដំណើរតាមរថយន្ត សូមចូលទៅកាន់តំណភ្ជាប់នេះ។ មានកន្លែងចតរថយន្តស្ថិតនៅក្បែរមជ្ឈមណ្ឌលនោះ។

**ជំនួយផ្នែកបកប្រែ៖** ការបកប្រែតាមប្រព័ន្ធ Zoom រួមមាន ភាសាអេស្ប៉ាញ ចិនកុកងឺ វៀតណាម ក្រេអូលហៃទី កាប់វែរក្រេអូល ព័រទុយហ្គាល់ និងភាសាសញ្ញាអាមេរិក (ASL) នឹងមានផ្តល់ជូនតាមអនឡាញតាមប្រព័ន្ធ Zoom ។ នឹងមានផ្តល់ជូនការបកប្រែផ្ទាល់មាត់ជាភាសា អេស្ប៉ាញ ចិនកុកងឺ ខ្មែរ និងភាសាកាប់វែរក្រេអូលដោយផ្ទាល់។ ប្រសិនបើអ្នកត្រូវការការបកប្រែផ្ទាល់មាត់ជាភាសាផ្សេងទៀត ឬការសម្របសម្រួលបន្ថែមណាមួយ សូមបញ្ជូលសំណើនោះក្នុងអ៊ីមែលទៅកាន់ meetings@erg.com ។ សំណើត្រូវតែដាក់ជូនរយៈពេល 48 ម៉ោងមុនពេលកិច្ចប្រជុំចាប់ផ្តើម។ ដើម្បីទទួលបានព័ត៌មាននេះជាភាសាអង់គ្លេស អក្សរពុម្ពធំ ឬអក្សរស្ទាបសម្រាប់មនុស្សពិការភ្នែក សូមហៅទូរសព្ទទៅលេខ 1-877-623-6765 ។ TTY៖ 1877-623-7773 ។

**ច្បាប់ប្រជុំដោយបើកចំហ៖** ក្រុមប្រឹក្សា EJ ប្រតិបត្តិការក្រោមច្បាប់ប្រជុំដោយបើកចំហ [https://www.mass.gov/the-open-meeting-law] ហើយស្វាគមន៍សមាជិកសាធារណជនទាំងអស់ដែលមានបំណងចង់ចូលរួមសង្កេតកិច្ចប្រជុំផ្លូវការរបស់ខ្លួន។

**ព័ត៌មានបន្ថែមអំពីក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន (EJC)៖** EJC គឺជាក្រុមប្រឹក្សាដែលត្រូវបានតែងតាំងដោយអភិបាលដើម្បីផ្តល់យោបល់ និងផ្តល់អនុសាសន៍ដល់រដ្ឋមន្ត្រី EEA អំពីគោលនយោបាយ និងស្តង់ដាដែលពាក់ព័ន្ធ ដើម្បីសម្រេចបាននូវគោលការណ៍យុត្តិធម៌បរិស្ថាននានា។ គោលការណ៍ទាំងនេះត្រូវបានកំណត់ដោយច្បាប់របស់រដ្ឋថាជា "គោលការណ៍ដែលគាំទ្រការការពារពីការបំពុលបរិស្ថាន និងលទ្ធភាពក្នុងការរស់នៅក្នុងបរិស្ថានស្អាត និងមានសុខភាពល្អ ដោយមិនគិតពីពូជសាសន៍ ពណ៌សម្បុរ ប្រាក់ចំណូល វណ្ណៈ ពិការភាព អត្តសញ្ញាណយេនឌ័រ ទំនោរផ្លូវភេទ ដើមកំណើតជាតិ ជាតិសាសន៍ ឬពូជពង្ស ជំនឿសាសនា ឬជំនាញភាសាអង់គ្លេស ដែល

រួមមាន៖ (i) ការចូលរួមយ៉ាងសកម្មរបស់ប្រជាជនទាំងអស់ពាក់ព័ន្ធនឹងការអភិវឌ្ឍ ការអនុវត្ត និងការពង្រឹងការអនុវត្តច្បាប់ បទបញ្ញត្តិ និងគោលនយោបាយបរិស្ថាន ដោយរួមទាំងគោលនយោបាយស្តីពីបម្រែបម្រួលអាកាសធាតុ និង (ii) បំណែងចែកប្រកបដោយសមធម៌នូវថាមពល និងផលប្រយោជន៍បរិស្ថាន ព្រមទាំងបន្ទុកបរិស្ថាន។” ច្បាប់នេះត្រូវបានចែងត្រង់ផ្នែក 62L ក្នុងតំណនេះ៖ [https://malegislature.gov/Laws/SessionLaws/Acts/2021/Chapter8] ។

ព័ត៌មានបន្ថែមអំពី EJC កិច្ចប្រជុំនាពេលខាងមុខ និងសំឡេងថតកិច្ចប្រជុំកន្លងមក អាចរកបាននៅទីនេះ៖ https://www.mass.gov/orgs/environmental-justice-council ។ សូមចុចលើពាក្យ “Select Language” នៅខាងលើផ្នែកខាងស្តាំនៃគេហទំព័រ ដើម្បីបកប្រែទំព័រនេះ។

សូមអរគុណ!

María Belén Power
អនុរដ្ឋមន្ត្រីសមធម៌និងយុត្តិធម៌បរិស្ថាន
ការិយាល័យប្រតិបត្តិកិច្ចការថាមពលនិងបរិស្ថាន